ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តព្រៃវែង
លេខ:..០៥៧..ដ.ក/៣វ

អគ្គនាយកដ្ឋានគោលនយោបាយ
មុខងារសាធារណៈ
ចូល លេខ:....០៨១..........
ថ្ងៃទី ០៤,០៨,១៦ ម៉ោង ០៣:០០
បញ្ជូន.......................

# ដីកា
# ស្តីពី
# ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ
# នៅរដ្ឋបាលខេត្តព្រៃវែង

## អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៥/១១២២ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ ត្រាស់បង្គាប់តែងតាំង អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- លិខិតលេខ ១៨៤៦ មស.គករ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ

# សម្រេច

**ប្រការ១** :

ត្រូវបានបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅរដ្ឋបាលខេត្តព្រៃវែង ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ជា សុំមេធី** | អភិបាលនៃគណៈអភិបាលខេត្ត | ប្រធាន |
| ២. លោក | **ចាន់ ថា** | អភិបាលរងនៃគណៈអភិបាលខេត្ត | អនុប្រធាន |
| ៣. លោក | **ញ៉ែម សុខជា** | ប្រធានមន្ទីរមុខងារសាធារណៈខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៤. លោក | **អ៊ុយ សាគុណា** | នាយករដ្ឋបាលសាលាខេត្ត | សមាជិក |
| ៥. លោក | **ទួន សុគន្ធ** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ៦. លោក | **ស៊ិន ចំណាន** | ប្រធានរតនាគារខេត្ត | សមាជិក |
| ៧. លោក | **អភិបាលនៃគណៈអភិបាលក្រុង ស្រុក** | | សមាជិក |
| ៨. លោក | **ផាត សុភិច** | ប្រធានមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចខេត្ត | សមាជិក |
| ៩. លោក | **ឈុនលី តីរុណា** | អនុប្រធានមន្ទីរមុខងារសាធារណៈខេត្ត | សមាជិក |
| ១០. លោក | **ឈាង សុវណ្ណារ៉ា** | នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស | សមាជិក |
| ១១. លោក | **យ៉ន ម៉ូរី** | ប្រធានការិយាល័យត្រួតពិនិត្យរដ្ឋបាលនិងបៀវត្ស | ជាមន្ត្រីបង្គោល |
| ១២. លោកស្រី | **ប៊ិន សុធា** | ប្រធានការិយាល័យក្របខណ្ឌនិងបណ្តុះបណ្តាល | ជាមន្ត្រីបង្គោល |

**ប្រការ២** :

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅរដ្ឋបាលខេត្តព្រៃវែង មានតួនាទីភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខប្រធានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រងនិងដឹកនាំគ្រប់ការងារពាក់ព័ន្ធទៅនឹងកម្មវិធីយុទ្ធសាស្ត្រនិងសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- សម្របសម្រួលការងារកែទម្រង់រដ្ឋបាលសាធារណៈ រវាងក្រសួង ស្ថាប័នសាមីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ។
- សម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពការងារកែទម្រង់រដ្ឋបាលសាធារណៈ ។
- ត្រូវរៀបចំផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈជូនប្រធានស្ថាប័នសាមីជាប្រចាំ ។

- ត្រូវរាយការណ៍អំពីវឌ្ឍនភាពឱ្យបានទៀងទាត់ រៀងរាល់ត្រីមាសមកលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈតាមរយៈមន្ត្រីបង្គោលក្នុងការស្វែងរកនិងប្រមូលព័ត៌មាន ការរៀបចំផែនការសកម្មភាព ការអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ការរៀបចំរបាយការណ៍ និងបញ្ជូនរបាយការណ៍សង្ខេបនូវសូចនាករដែលទាក់ទងទៅ នឹងវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈរបស់សាមីក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមកលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ឬនាយកដ្ឋានជំនាញនៃក្រសួងមុខងារសាធារណៈ។ ជាពិសេសមន្ត្រីបង្គោលត្រូវចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ការអនុវត្តកម្មវិធីជាតិ កំណែទម្រង់រដ្ឋបាលសាធារណៈ។

**ប្រការ៣** :

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងដីការនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៤** :

នាយករដ្ឋបាលសាលាខេត្ត ប្រធានមន្ទីរមុខងារសាធារណៈខេត្ត អភិបាលនៃគណៈអភិបាលក្រុង ស្រុក ប្រធានមន្ទីរ អង្គភាពជុំវិញខេត្ត នាយកទីចាត់ការ និងប្រធានអង្គភាពចំណុះរដ្ឋបាលខេត្ត និងសាមីខ្លួនដូចមានចែងក្នុងប្រកា១ខាងលើ ត្រូវអនុវត្តដីកានេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ព្រៃវែង,ថ្ងៃទី..២៩.....ខែកក្កដា..ឆ្នាំ២០១៦

**អភិបាលខេត្ត**

ជា_សុមេធី

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ដូចប្រកា៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ